# មេរៀនទី ១៣៩៖ លោកអេលីយ៉ាជួយស្ត្រីមេម៉ាយ

## ១ ពង្សាវតារក្សត្រ ១៧៖៧-២៤

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/CCA5ubS49ql

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/pLHKBJ3ga4Q

**គោលបំណង៖** យើងទូលសូមពីទ្រង់ដោយទុកចិត្ត។

**ខគម្ពីរចងចាំ៖** រ៉ូម ៨៖២៨ *"តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សំរាប់សេចក្ដីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅមក តាមព្រះដំរិះទ្រង់។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ពេលដែលព្រះវិញ្ញាណបរិសុទ្ធ https://youtu.be/RODHIMCRzw4

២. ហូសាណា https://youtu.be/QWQ47zCVaCw

៣. ខ្ញុំនឹងទុកចិត្តទ្រង់ https://youtu.be/WCZlwlstAzc

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )



### ៣. ល្បែងកំសាន្ត «យកដបដាក់ចូលក្នុងចាន»

សម្ភារៈដែលត្រូវការ៖ ខ្សែ ដបទឹក កូនចានចង្កឹះ

១. ចងខ្សែវែង៧៥ ទៅនឹងដបទឹក

២. ជ្រើសកុមារ៥នាក់ក្នុងមួយក្រុម ហើយចងខ្សែដែលចងភ្ជាប់ទៅនឹងដបទឹកនោះ ជុំវិញចង្កេះ របស់ពួកគេ

៣. ពួកគេទាំងអស់គ្នាត្រូវនាំយកដបទឹកនោះទៅ ចុងថ្នាក់រៀន ហើយដាក់វាចូលទៅក្នុងកូនចាន ដែលនៅទីនោះ ដោយឲ្យដបទឹកឈរ។

៤.ក្រុមណាដែលអាចយកដបទឹកដាក់ក្នុងចានទាំងបីបានមុនគេក្រុមនោះជាអ្នកឈ្នះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ពួកគេមានការពិបាកក្នុងការទុកចិត្តគ្នា និងពិបាកក្នុងក្នុងការជួយគ្នាទៅវិញទៅមក ដើម្បីទទួលបានជោគជ័យក្នុងការលេងល្បែងនេះ។ យើងក៏ពិបាកក្នុងការស្តាប់គ្នាទៅវិញទៅមកដែរ។ ក៏ដូចគ្នានេះដែរ យើងត្រូវតែទុកចិត្តព្រះ និងស្តាប់បង្គាប់ទ្រង់។

### ៤. ការណែនាំមេរៀន

ការមានទំនុកចិត្តលើនរណាម្នាក់គឺមានន័យថា អ្នកមានជំនឿចិត្ត និងទុកចិត្តចំពោះបុគ្គលម្នាក់នោះយ៉ាងខ្លាំង ទៅលើភាពស្មោះត្រង់និងការជឿជាក់។ មានន័យថា យើងជឿថាបុគ្គលនោះ នឹងធ្វើដូចដែលគេនិយាយ ហើយនឹងប្រព្រឹត្តដោយយុត្តិធម៌ត្រឹមត្រូវ។ តើអ្នកទុកចិត្តលើនរណា? តើអ្នកទុកចិត្តឪពុកម្តាយរបស់អ្នកដែរឬទេ? ជីដូនជីតា? ពូមីង? ឬក៏មិត្តរបស់អ្នកដែរឬទេ? ថ្ងៃនេះ យើងនឹងរៀនអំពីព្យាការីម្នាក់ និងស្ត្រីម្នាក់ដែលទុកចិត្តព្រះ នៅពេលពួកគេមានបញ្ហា។

### ៥. រឿងនៅក្នុងព្រះគម្ពីរ

បន្ទាប់ពីកូនប្រុសរបស់ស្តេចសាឡូម៉ូន គឺរេហូបោមដែលបានឡើងធ្វើជាស្តេចបន្ទាប់របស់យូដា ព្រះគម្ពីរ

បាននិយាយថា **១ពង្សាវតារក្សត្រ ១៤៖២២** “ពួកយូដាក៏ប្រព្រឹត្តអាក្រក់លាមកនៅ ចំពោះព្រះនេត្រ ព្រះយេហូវ៉ា។” រាជាណាចក្រមួយទៀតត្រូវបានគេហៅថា អ៊ីស្រាអែលក៏បានធ្វើអំពើលាមកអាក្រក់នៅចំពោះព្រះនេត្រព្រះយេហូវ៉ាដែរ។រឿងថ្ងៃនេះកើតឡើងក្នុងរាជាណាចក្រអ៊ីស្រាអែលក្រោមការ ដឹកនាំរបស់ស្តេចអ័ហាប់។ ទ្រង់ជាស្តេចអាក្រក់ ហើយបានថ្វាយបង្គំរូបព្រះបាល។ ពួកគេជឿថាព្រះបាលបានប្រទានភ្លៀងដល់ពួកគេ ដូច្នេះ ដើម្បីបង្ហាញពួកគេថា ព្រះបាលគ្មានអំណាចនោះព្រះបានធ្វើឲ្យមានគ្រោះរាំងស្ងួតក្នុងនគររបស់ពួកគេ។

មនុស្សម្នាជាច្រើនក្នុងរាជណាចក្រអ៊ីស្រាអែល ត្រូវរងទុក្ខវេទនា ហើយថ្ងៃនេះរឿងនៅក្នុងព្រះគម្ពីររបស់យើងគឺនិយាយអំពីស្ត្រីមេម៉ាយម្នាក់ ដែលរៀនក្នុងការទុកចិត្តព្រះ។ ស្ត្រីមេម៉ាយគឺជាស្ត្រីដែលប្តីរបស់គាត់បានស្លាប់ចោលគាត់។ នៅជំនាន់ព្រះគម្ពីរសញ្ញាចាស់ ស្ត្រីមេម៉ាយពេលខ្លះមិនមានអ្នកមើលថែយកចិត្តទុកដាក់ ហើយរស់នៅក្នុងភាពក្រីក្រ។ ហោរាអេលីយ៉ាបានស្នាក់នៅក្នុងទីក្រុងមួយជិតកន្លែង ដែលស្ត្រីមេម៉ាយនោះរស់នៅ ហើយព្រះបានប្រាប់អេលីយ៉ាឲ្យទៅសុំអាហារខ្លះពីស្ត្រីម្នាក់នោះ។ អេលីយ៉ាទុកចិត្តព្រះហើយនិងស្តាប់បង្គាប់ព្រះ។ នៅពេលដែលអេលីយ៉ាបានជួបនាងគាត់បានសុំទឹកនាងផឹក និងនំប៉័ងមួយចំនួន។ ស្ត្រីមេម៉ាយនោះបានប្រាប់អេលីយ៉ាថា នាងមានតែម្សៅ១ក្តាប់នៅក្នុងខាប់ និងប្រេងបន្តិចបន្តួចនៅដប ដែលទុកចំអិនសម្រាប់នាងនិងកូនរបស់នាងបានមួយពេលប៉ុណ្ណោះ។ អេលីយ៉ាបានប្រាប់ស្ត្រីមេម៉ាយនោះថា កុំឲ្យខ្លាចឡើយ សូមទៅធ្វើដូចជាអ្នកបានថាចុះ តែសូមធ្វើនំ១យ៉ាងតូចមកឲ្យខ្ញុំជាមុនសិន រួចសឹមធ្វើសំរាប់អ្នក និងកូនអ្នកចុះ។

ស្ត្រីមេម៉ាយនិងកូនរបស់នាងគឺពិតជាឃ្លានខ្លាំងណាស់។ តើអ្នកគិតថាវាជារឿងត្រឹមត្រូវដែរឬទេ ដែលស្ត្រីមេម៉ាយនោះត្រូវធ្វើនំសម្រាប់អេលីយ៉ាជំនួសឲ្យនាងនិងកូនរបស់នាងនោះ? ទេ វាគឺពិបាកណាស់។ កូនប្រុសរបស់គាត់គួតែប្រាប់ម្តាយថា មិនចាំបាច់ស្តាប់បង្គាប់ព្រះទេ។ ប៉ុន្តែម្តាយនិងកូនបានធ្វើតាមនូវអ្វីដែលអេលីយ៉ាបានសុំ។ អេលីយ៉ាបានប្រាប់ស្ត្រីមេម៉ាយថា ម្សៅក្នុងខាប់នោះនឹងមិនដែលផុតទៅ ហើយប្រេងក្នុងដបក៏មិនដែលរលោះឡើយ ដោយសារតែនាងស្តាប់បង្គាប់ព្រះ។ ហើយព្រះតែងតែរក្សាការសន្យារបស់ទ្រង់។ សូម្បីតែបន្ទាប់ពីនាងបានប្រើម្សៅ និងប្រេងទាំងអស់របស់នាងដើម្បីធ្វើ អាហារសម្រាប់អេលីយ៉ាក៏ដោយ ជារៀងរាល់ថ្ងៃតែងតែមានម្សៅ និងប្រេងបន្ថែមទៀតសម្រាប់ធ្វើអាហារសម្រាប់ស្ត្រីមេម៉ាយ និងកូនប្រុសរបស់គាត់រហូតដល់គ្រោះរាំងស្ងួតបានបញ្ចប់។

អេលីយ៉ាទុកចិត្តព្រះខ្លាំងណាស់គាត់ទៅគ្រប់ទីកន្លែងដែលព្រះប្រាប់គាត់ឲ្យទៅ។ ហើយព្រះក៏បានប្រទានពរដល់គាត់តាមរយៈការនោះដែរ។ ស្ត្រីមេម៉ាយក៏ទុកចិត្តព្រះខ្លាំងណាស់ដែរ ដែលគាត់បានចែករំលែកអាហារបន្តិចបន្តួចដែលគាត់មានទៅអេលីយ៉ា។ ហើយព្រះក៏បានប្រទានពរដល់នាងតាមរយៈការនោះ។ ព្រះជាម្ចាស់សប្បាយព្រះទ័យនៅពេលដែលយើងទុកចិត្តទ្រង់។ ហើយនេះគឺជាអ្វីដែលព្រះចង់ឲ្យយើងធ្វើ។ មានរឿងរ៉ាវជាច្រើនកើតឡើងចំពោះយើងដែលធ្វើឲ្យយើងមានការភ័យខ្លាចនិងព្រួយបារម្ភ។ ប៉ុន្តែព្រះសប្បាយចិត្តនៅពេលដែលយើងទុកចិត្តលើទ្រង់ហើយអនុញ្ញាតឲ្យទ្រង់ជួយដល់យើង។ ព្រះចង់ឲ្យយើងទុកចិត្តលើទ្រង់ ហើយទ្រង់នឹងការពារយើង។

**៦. សំនួរពិភាក្សា**

១. តើព្រះមួយណាដែលអ៊ីស្រាអែលជឿជំនួសព្រះដ៏ពិត? *(រូបព្រះបាល)*

២. តើអ៊ីស្រាអែលគិតថាព្រះបាលមានអំណាចផ្តល់អ្វី? *(ផ្តល់ទឹកភ្លៀង)*

៣. តើព្រះបានធ្វើអ្វីដើម្បីបង្ហាញថា ព្រះបាលគ្មានអំណាច?

*(ទ្រង់បានបង្អាក់ទឹកភ្លៀង ហើយបង្កឲ្យមានគ្រោះរាំងស្ងួត ជនជាតិអ៊ីស្រាអែលបានអធិស្ឋានដល់ ព្រះបាលសុំភ្លៀង ប៉ុន្តែគ្មានភ្លៀងធ្លាក់មកទេ ព្រោះព្រះបាលគ្មានអំណាច)*

៤. តើស្ត្រីមេម៉ាយបង្ហាញដោយរបៀបណាថានាងទុកចិត្តព្រះ?

*( នាងបានប្រើម្សៅ និងប្រេងទាំងអស់របស់នាងដើម្បីធ្វើម្ហូបឲ្យអេលីយ៉ាដោយសេចក្ដីជំនឿ )*

៥. តើមានអ្វីកើតឡើងពេលនាងទុកចិត្តព្រះក្នុងគ្រាលំបាក?

*(ម្សៅនិងប្រេងរបស់នាងមិនដែលអស់ នោះទេ)*

៦. តើអ្នកអាចធ្វើអ្វីបានពេលដែលអ្នកភ័យខ្លាច ច្របូកច្របល់ ឬមានបញ្ហា? *(ជឿថាព្រះនឹងជួយយើង)*

**៧. ល្បែងកំសាន្ត «បោះបាល់»**

សម្ភារៈដែលត្រូវការៈ បាល់២ ឬផ្លែឈើមូលៗ



១. ឲ្យកុមារទាំងអស់ឈរជាជួរតែមួយនៅកណ្ដាលថ្នាក់រៀន

២. គ្រូម្នាក់ត្រូវឈរនៅពីមុខកុមារទាំងអស់ ហើយគ្រូម្នាក់ទៀតត្រូវឈរនៅខាងក្រោយកុមារ។ គ្រូទាំងពីរ ត្រូវរមៀលបាល់ពីមុខទៅក្រោយ ពីក្រោយមកខាងមុខ នៅចន្លោះជើងកុមារទាំងអស់។

៣. ប្រសិនបើបាល់ប៉ះជើងកុមារណាម្នាក់នោះគេនឹងចាញ់ល្បែងនេះ។ ដូច្នេះនៅពេលដែលបាល់មកដល់ ជិតជើងរបស់ពួកគេត្រូវកន្ទេកជើងឲ្យកាន់តែធំ។ ប្រសិនបើបាល់ប៉ះជើងកុមារនោះគេត្រូវឈរនៅម្ខាង។

៤. នៅពេលដែលបាល់មិនបានប៉ះកុមារណាម្នាក់ហើយបាល់រមៀលដល់ក្រោយនោះ គ្រូត្រូវបន្តរមៀលបាល់នេះ។

៥. បន្តលេងល្បែងនេះរហូតដល់នៅសល់កុមារតែ ៣ ទៅ ៥នាក់ នោះពួកគេនឹងឈ្នះល្បែងនេះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា កុមារត្រូវស្ដាប់តាមការណែនាំពីគ្រូដូចស្ត្រីមេម៉ាយបានស្ដាប់បង្គាប់អេលីយ៉ាដែរ។ យើងត្រូវទុកចិត្តថា ព្រះនឹងមើលថែយើង ពេលយើងស្ដាប់បង្គាប់ទ្រង់។

**៨. ខគម្ពីរចងចាំ**

**រ៉ូម ៨:២៨** *"តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សំរាប់សេចក្ដីល្អដល់ពួកអ្នក ដែលស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅមកតាមព្រះដំរិះទ្រង់។"*

**៩. ហាត្ថកម្ម**

សូមផាត់ពណ៌រូបភាព "ស្ត្រីមេម៉ាយទុកចិត្តព្រះ"។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូៈ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
ការរីកលូតលាស់នៃជំនឿលើព្រះយេស៊ូវ នាំមកនូវសន្តិភាពនៃចិត្ត សូម្បីតែនៅពេលមានបញ្ហាក្នុងជីវិតក៏ដោយ។ អេលីយ៉ាជាបុរសម្នាក់ដែលគ្មានដី ជម្រក អាហារ ទឹក ឬអ្នកដើរជាមួយទេ។ ប៉ុន្តែជំនឿរបស់គាត់បានអនុញ្ញាតឲ្យគាត់បម្រើព្រះដោយស្ម័គ្រចិត្តនិងការដឹងគុណ។ តើអ្នកខ្លាចអ្វីជាងគេ? តើការភ័យខ្លាចនោះ បានរាំងសមត្ថភាពរបស់អ្នកក្នុងការទទួលបទពិសោធន៍ពីព្រះយ៉ាងដូចម្ដេច? សូមអធិស្ឋានឥឡូវនេះ ដើម្បីចាប់ផ្ដើមដំណើរការនៃការដោះលែងការភ័យខ្លាចនោះ ហើយជឿទុកចិត្តលើព្រះ ដើម្បីទទួលបាននូវការផ្គត់ផ្គង់តាមរយៈការនោះ។

# សូមផាត់ពណ៌រូបភាព "ស្ត្រីមេម៉ាយទុកចិត្តព្រះ"



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________

______________________________________________

______________________________________________

______________________________________________